# មេរៀនទី ៤៤: សុបិន្តរបស់យ៉ូសែប

## លោកុប្បត្តិ ៣៧:១-១១

**គោលបំណង៖** ព្រះចង់ឱ្យយើងស្រលាញ់គ្រួសាររបស់យើង។

**ខគម្ពីរចងចាំ៖ អេភេសូ ៦:១** “*ក្មេងរាល់គ្នាអើយ ចូរស្តាប់បង្គាប់មាតាបិតាខ្លួនក្នុងព្រះអម្ចាស់ ដ្បិតធ្វើ ដូច្នោះទើបបានត្រូវ។*”

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**

នៅពេលដែលយើងដើរតាមព្រះគ្រីស្ទ និងលូតលាស់នៅក្នុងសេចក្តីស្រឡាញ់ព្រះ យើងពិតជាចង់បង្ហាញពីសេចក្តីស្រឡាញ់របស់ទ្រង់ទៅចំពោះគ្រួសាររបស់យើង។ កូនៗរបស់យ៉ាកុបទាំងអស់ត្រូវការសេចក្តីស្រលាញ់ និងចង់ក្លាយជាកូនសំណព្វរបស់ឪពុកខ្លួន។ សូមអាន **លោកុប្បត្តិ ៣៧:៣-៤**ម្តងទៀត។ តើក្តីស្រលាញ់លំអៀងរបស់យ៉ាកុបចំពោះយ៉ូសែបវាធ្វើឲ្យប៉ះពាល់ដល់កូនៗផ្សេងទៀតយ៉ាងណាខ្លះ? ដូចដែលអ្នកបង្រៀនកុមារៗដែរ សូមចាំថាសិស្សគ្រប់រូបគឺសុទ្ធតែពិសេស ហើយពួកគេចង់បានការស្រលាញ់ពីគ្រូរបស់ពួកគេ។ ក្នុងសប្តាហ៍នេះសូមបង្ហាញក្តីស្រលាញ់ដ៏វិសេសនោះទៅកាន់សិស្សៗរបស់អ្នក។

**ចំរៀង៖** ១. ព្រះអម្ចាស់យើងល្អណាស់ ២.ក្តីស្រឡាញ់នៃព្រះផ្អែមហើយអស្ចារ្យ ៣. សូមព្រះអង្គអង្រួនយើង

**១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបើក)*

**២. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**៣. ល្បែងកំសាន្ត** «ចាប់ក្រុមតាមលេខ»




១. ឱ្យកុមារៗរាំតាមភ្លេង ហើយពេលដែលគ្រូហៅលេខណាមួយ កុមារៗត្រូវតែត្រៀមខ្លួនរត់រកគ្នាឲ្យបានគ្រប់តាមចំនួនលេខដែលគ្រូហៅ។

២. ឧទាហរណ៍៖ បើគ្រូហៅលេខ៣កុមារត្រូវចាប់គ្នា៣នាក់។

៣. លេងល្បែងនេះម្តងហើយម្តងទៀត រហូតដល់កុមារសប្បាយរីករាយ ។

**៤. ការណែនាំមេរៀន**

ព្រះគម្ពីរគឺជាសំបុត្រនៃសេចក្តីស្រលាញ់ដែលព្រះផ្ញើមកយើងរាល់គ្នា។ តាមរយៈព្រះគម្ពីរ យើងបានដឹងពីព្រះវិញ្ញាណបរិសុទ្ធដ៏ពិត ដឹងពីការអស្ចារ្យទាំងឡាយ ស្គាល់ព្រះអាទិករដែលជាអ្នកយាងមករកមនុស្សដោយសេចក្តីស្រលាញ់ តាំងពីថ្ងៃដំបូងដែលព្រះអង្គបានបង្កើតយើងមក។ យើងបានដឹងថាព្រះអង្គស្រលាញ់យើង ហើយគ្មានសេចក្តីស្រលាញ់ណាប្រៀបស្មើនឹងក្តីស្រលាញ់ទ្រង់ឡើយ។ ក្តីស្រលាញ់ទ្រង់គឺគ្រប់ល័ក្ខណ៍ អត់ធ្មត់ ចិត្តល្អ យោគយល់ លះបង់ បរិសុទ្ធ និងមិនដែលបោះបង់ចោលយើងឡើយ។ ហើយអ្វីដែលវិសេសជាងគេនោះគឺជាសេចក្តីស្រឡាញ់របស់ព្រះ គឺជាអំណោយដែលទ្រង់ប្រទានមកយើងមុនពេលយើងស្គាល់ទ្រង់ទៅទៀត។ ក្តីស្រឡាញ់ទ្រង់បានចាក់បង្ហូរមកដល់យើងតាំងពីយើងនៅជាមនុស្សដែលមានបាបនៅឡើយ (**រ៉ូម ៥:៨**)។ នេះគឺ

មានន័យថាព្រះបានស្រលាញ់យើងបើទោះបីយើងជាមនុស្សមិនល្អក៏ដោយ! នេះគឺជាក្ដីស្រលាញ់ដ៏ស្វារ្យរបស់ព្រះ ហើយទ្រង់ចង់ឱ្យយើងចែករំលែកក្ដីស្រលាញ់របស់ទ្រង់ជាមួយនឹងក្រុមគ្រួសាររបស់យើងដែរ។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ថ្ងៃនេះយើងនឹងស្វែងយល់ពីគ្រួសារមួយនៅក្នុងព្រះគម្ពីរ ដែលទទួលបានក្ដីស្រលាញ់គ្រប់ល័ក្ខណ៍ពីព្រះជាម្ចាស់ ប៉ុន្តែពួកគេមិនបានចែករំលែកក្ដីស្រលាញ់នោះជាមួយគ្នាបានល្អទេ។ ព្រះស្រលាញ់យ៉ាកុបដោយក្ដីស្រលាញ់គ្រប់ល័ក្ខណ៍របស់ទ្រង់ តែយ៉ាកុបមិនបានស្រលាញ់ក្រុមគ្រួសារគាត់ឲ្យបានគ្រប់ល័ក្ខណ៍នោះទេ។ យ៉ាកុបបានរស់នៅលើទឹកដីកាណានជាមួយកូនៗទាំង១២នាក់របស់គាត់។ គាត់ស្រលាញ់កូនៗរបស់គាត់ទាំងអស់ ប៉ុន្តែមានកូនប្រុសម្នាក់ដែលគាត់ស្រឡាញ់ជាងគេ។

យ៉ូសែបជាកូនប្រុសសំណព្វរបស់យ៉ាកុប។ យ៉ូសែបមានអាយុ១៧ឆ្នាំ ជាកូនទី១១ក្នុងចំណោមកូនទាំង ១២នាក់របស់យ៉ាកុប។ យ៉ូសែបជាកូនដែលកើតពីរ៉ាជែលជាប្រពន្ធដែលយ៉ាកុបស្រលាញ់ជាងគេ។ រាល់ថ្ងៃយ៉ូសែបទៅឃ្វាលចៀមមួយបងៗ ប៉ុន្តែពេលបងៗរបស់គាត់ធ្វើការមិនសូវបានល្អ យ៉ូសែបក៏បានរាយការណ៍ប្រាប់ឪពុករបស់គេ។ ក្រៅពីពូកែខាងរាយការណ៍ហើយ យ៉ូសែបក៏បានទទួលបានអាវពិសេសដែលមានពណ៌ច្រើនពីយ៉ា-កុបថែមទៀតផង។ យ៉ាកុបមិនបានឱ្យអាវនេះទៅកូនប្រុសផ្សេងៗទេ បងៗរបស់យ៉ូសែបខឹងនឹងគាត់ដោយសារយ៉ូសែបជាកូនសំណព្វ ហើយពួកគេច្រណែនព្រោះពួកគេមិនបានទទួលអាវពណ៌ច្រើនពីឪពុកដូចជាយ៉ូសែប។ ពួកគេមិនអាចនិយាយពាក្យល្អៗជាមួយប្អូនប្រុសរបស់ពួកគេបានទេ។

យប់មួយយ៉ូសែបបានយល់សប្ដិឃើញរឿងមួយ ហើយគាត់បានប្រាប់បងៗគាត់ពីអ្វីដែលគាត់បានសុបិន្តឃើញនោះ។ គាត់បាននិយាយថា "ខ្ញុំឃើញយើងទាំងអស់គ្នាកំពុងចងកណ្ដាប់ស្រូវនៅវាលស្រែ ពេលនោះស្រាប់តែកណ្ដាប់របស់បងៗបានមកព័ទ្ធជុំវិញកណ្ដាប់ខ្ញុំ ហើយនាំគ្នាក្រាបថ្វាយបង្គំកណ្ដាប់របស់ខ្ញុំ" បងៗរបស់គាត់មិនសប្បាយចិត្តជាមួយការយល់សុបិន្តនេះទេ ពីព្រោះស្ដាប់ទៅដូចជាយ៉ូសែបគិតថាគាត់ល្អជាងបងៗរបស់គាត់ ហើយបង្ហាញថាយ៉ូសែបនឹងត្រួតត្រាលើពួកបងៗគាត់ ពេលនោះពួកគេក៏ចាប់ផ្ដើមស្អប់យ៉ូសែប។

យ៉ូសែបមិនបានយកចិត្តទុកដាក់ជាមួយនិងអារម្មណ៍បងៗរបស់គាត់ទេ។ ក្រោយមកគាត់បានយល់សប្តិម្តងទៀត គាត់បានប្រាប់បងៗនិងឪពុករបស់គាត់ពីសុបិន្តនោះ "យ៉ូសែបបាននិយាយថា៖ ខ្ញុំសុបិន្តឃើញព្រះអាទិត្យព្រះចន្ទ និងផ្កាយ១១ដួងបានក្រាបថ្វាយបង្គំខ្ញុំ"។ ឪពុកគាត់ឆ្ងល់ចំពោះសុបិន្តរបស់យ៉ូសែប តែបងៗរបស់គាត់វិញមានអារម្មណ៍ខឹងចំពោះយ៉ូសែបរឹតតែខ្លាំងឡើង។

ព្រះស្រលាញ់យ៉ាកុបនិងក្រុមគ្រួសាររបស់គាត់ដោយក្ដីស្រលាញ់គ្រប់ល័ក្ខណ៍របស់ទ្រង់។ យ៉ាកុបក៏ស្រលាញ់ព្រះផងដែរ ប៉ុន្តែគាត់មិនបានស្រលាញ់ព្រះនិងកូនៗរបស់របស់គាត់ដោយក្ដីស្រលាញ់គ្រប់ល័ក្ខណ៍នោះទេ។ ហើយកូនៗរបស់គាត់ក៏មិនបានស្រលាញ់គ្នាទៅវិញទៅមកជាមួយនឹងក្ដីស្រលាញ់របស់ព្រះដែរ។ ហើយពួកគេគឺមិនមានក្ដីសុខនោះទេ។

ពេលខ្លះនៅក្នុងគ្រួសារអាចមានក្ដីស្រលាញ់និងមានទំនាក់ទំនងជាមួយគ្នាបានយ៉ាងល្អ។ តែពេលខ្លះទៀតយើងក៏អាចនឹងមានបញ្ហានៅក្នុងគ្រួសារស្រដៀងទៅនឹងគ្រួសាររបស់យ៉ូសែបដែរ។ យើងអាចនឹងឈ្លោះប្រកែកគ្នា អន់

ចិត្តរវាងគ្នានឹងគ្នា ឬក៏អួតអាងដាក់គ្នាក៏មាន។ ទោះបីជាយើងមិនបានបង្ហាញក្ដីស្រលាញ់គ្រប់ល័ក្ខណ៍ដាក់គ្នាក៏ដោយ ក៏ព្រះនៅតែបង្ហាញក្ដីស្រលាញ់គ្រប់លក្ខណ៍របស់ទ្រង់ចំពោះយើងដែរ។ ព្រះតែងតែស្រលាញ់យើងដោយគ្រប់លក្ខណ៍ មិនថាយើងគិតអ្វី ឬប្រព្រឹត្តបែបណានោះទេ។

នៅសប្ដាហ៍ក្រោយយើងនឹងរៀនបន្ថែមទៀតពីអ្វីនឹងកើតឡើង នៅពេលដែលសមាជិកគ្រួសារមិនបានស្រលាញ់គ្នាទៅវិញទៅមកនោះ ។

**៦. សំនួរពិភាក្សា**

១. តើយ៉ូសែបមានបងប្អូនប៉ុន្មាននាក់? *១១នាក់*

២. តើអ្នកណាជាកូនសំណព្វរបស់យ៉ាកុប? *យ៉ូសែប*

៣. តើយ៉ាកុបបានឱ្យអ្វីទៅយ៉ូសែប? *អាវពណ៌ច្រើន*

៤. ហេតុអ្វីបានជាបងៗស្អប់យ៉ូសែប? *បងៗច្រណែនយ៉ូសែប*

៥.តើកូនៗស្រលាញ់ប៉ាម៉ាក់ និងបងប្អូនកូនដែរឬទេ?

*ទៅដល់ផ្ទះកូនត្រូវនិយាយថាខ្ញុំស្រលាញ់ ឪពុក ម្ដាយ និងបងប្អូន*

**៧. ខគម្ពីរចងចាំ អេភេសូ ៦:១**

**៨. ហាត្ថកម្ម**

១. ឱ្យកុមារកាត់ក្រដាសធ្វើជារូបបេះដូងហើយសរសេរពាក្យថា “ខ្ញុំស្រលាញ់.......”

២. ឱ្យកុមារផាត់ពណ៌អាវពណ៌ច្រើនរបស់យ៉ូសែប

**៩. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១០. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបិទ)*

# អាវពណ៌ច្រើនរបស់យ៉ូសែប



សូមសរសេរខគម្ពីរចងចាំ: ___________________________________

___________________________________________

___________________________________________